ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៧ សហវ.អ.ហ.ន.រអបន

ថ្ងៃ សុក្រ ១០ កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣

# សេចក្តីណែនាំ

## ស្តីពី

## ការបើកផ្តល់បៀវត្សប្រចាំខែមេសា និងខែតុលា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៦ និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

អនុលោមតាមអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៦ និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ បានសម្រេចផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៦ ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ក្នុងម្នាក់ជូនដល់មន្ត្រីរាជការស៊ីវិលនៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ មន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មន្ត្រីខុទ្ទកាល័យដូចមានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការដែលជាប្រធានស្ថាប័ន ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើដូចមានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីនៃការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតដែលកំពុងបម្រើការងារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយោធិននៃកងយោធពលខេមរភូមិន្ទ និងអតីតមន្ត្រីនគរបាលជាតិកម្ពុជា។ ចំពោះគ្រួសារជនពលី និងគ្រួសារជនមរណៈ ជាអតីតយុទ្ធជន ត្រូវបានផ្តល់ជូនប្រាក់ឧបត្ថម្ភនេះ ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ក្នុងមួយគ្រួសារ។ ប្រាក់ឧបត្ថម្ភនេះត្រូវបានផ្តល់សម្រាប់ម្នាក់ៗ ឬ មួយគ្រួសារតែមួយកន្លែងនិងមួយលើកប៉ុណ្ណោះ។

ដើម្បីធានាដល់ការបើកផ្តល់បៀវត្សប្រចាំខែមេសា និងខែតុលា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៦ និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

២៥៦៧ សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ អនុលោមតាមអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៦ និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ និងយោងសារាចរណែនាំលេខ០០៤ សហវ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ នៅរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ ជំហានទី១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម÷

**១.រដ្ឋបាលថ្នាក់ជាតិ**

**១.១.ការបើកបៀវត្សប្រចាំខែមេសា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី**

**ក.ករណីមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត"**

ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវរួតរះរៀបចំលិខិតយុត្តិការចំណាយពាក់ព័ន្ធ និងបោះផ្សាយ**អាណត្តិបើកប្រាក់បៀវត្សប្រចាំខែមេសា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ** និងដោយឡែក ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទនៅថ្នាក់កណ្តាលដែលអនុវត្តតាមនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗ ដែលមានរបបកំណត់ច្បាស់លាស់ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបង្កើត**ប្រតិបត្តិការចំណាយបៀវត្សប្រចាំខែមេសា ឆ្នាំ២០២៣** ដោយរួមបញ្ចូលប្រាក់**ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ** និងស្កែនលិខិតយុត្តិការចំណាយពាក់ព័ន្ធនៅក្នុងប្រព័ន្ធ FMIS ឱ្យបានត្រឹមត្រូវ រួចបញ្ជូនទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ (រតនាគារថ្នាក់កណ្តាល ឬ រតនាគាររាជធានី ខេត្ត) យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ដើម្បីធានាដល់ការបើកផ្តល់បៀវត្សប្រចាំខែមេសា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តែមួយលើកឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។

**ខ.ករណីពុំមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត"**

-ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទនៅថ្នាក់កណ្តាល ត្រូវរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដោយភ្ជាប់មកជាមួយនូវតារាងរាយលម្អិតចំនួនទឹកប្រាក់ដែលត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានឆាប់រហ័ស ជាមួយនឹងការបង្កើត**ប្រតិបត្តិការចំណាយ**ប្រាក់**ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ** (PO-Advanced) តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងស្កែនឯកសារពាក់ព័ន្ធឱ្យបានត្រឹមត្រូវ រួចបញ្ជូនទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ។ ផ្អែកតាមលិខិតអនុញ្ញាតផ្តល់បុរេប្រទានចេញដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបញ្ជូនមកដល់រតនាគារថ្នាក់កណ្តាលយ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ រតនាគារថ្នាក់កណ្តាល ត្រូវធ្វើការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដំណាលគ្នានឹងការបើកផ្តល់បៀវត្សប្រចាំខែមេសា ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលាមុនថ្ងៃពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ។ ចំពោះក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទនៅថ្នាក់កណ្តាល ដែលខកខានពុំបាន

រៀបចំលិខិតស្នើសុំថវិកាបុរេប្រទានបញ្ជូនទៅរតនាគារថ្នាក់កណ្តាល នោះរតនាគារថ្នាក់កណ្តាល ពុំមានមូលដ្ឋានក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិជូនឡើយ

-មន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានទៅរតនាគាររាជធានី ខេត្ត ដោយភ្ជាប់ជាមួយនូវតារាងរាយលម្អិតចំនួនទឹកប្រាក់ដែលត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភយ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ និងត្រូវចម្លងជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ០១ ច្បាប់។ យោងតាមលិខិតស្នើសុំថវិកាបុរេប្រទានរបស់មន្ទីរជំនាញរាជធានី ខេត្ត រតនាគាររាជធានី ខេត្ត ត្រូវធ្វើការបើកផ្តល់ថវិកាបុរេប្រទាននោះ ដំណាលគ្នានឹងការបើកផ្តល់បៀវត្សប្រចាំខែមេសា ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ ចំពោះមន្ទីរជំនាញរាជធានី ខេត្ត ដែលខកខានពុំបានរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានបញ្ជូនទៅរតនាគាររាជធានី ខេត្ត នោះរតនាគាររាជធានី ខេត្ត ពុំមានមូលដ្ឋានក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិជូនឡើយ។

**១.២.ការបើកបៀវត្សប្រចាំខែតុលា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ**

**ក.ករណីមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត"**

ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវរួតរះរៀបចំលិខិតយុត្តិការចំណាយពាក់ព័ន្ធ និងបោះផ្សាយ**អាណត្តិបើកប្រាក់បៀវត្សប្រចាំខែតុលា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ** និងដោយឡែកក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៅថ្នាក់កណ្តាលដែលអនុវត្តតាមនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានរបបកំណត់ច្បាស់លាស់ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបង្កើត**ប្រតិបត្តិការចំណាយបៀវត្សប្រចាំខែតុលា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ** នៅក្នុងប្រព័ន្ធ FMIS និងស្កេនលិខិតយុត្តិការចំណាយពាក់ព័ន្ធឱ្យបានត្រឹមត្រូវ រួចបញ្ជូនទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ (រតនាគារថ្នាក់កណ្តាល ឬ រតនាគាររាជធានី ខេត្ត) យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ដើម្បីធានាដល់ការបើកផ្តល់បៀវត្សប្រចាំខែតុលា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ តែមួយលើក ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យភ្ជុំបិណ្ឌ។

**ខ.ករណីពុំមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត"**

-ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទនៅថ្នាក់កណ្តាល ត្រូវរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ដោយភ្ជាប់មកជាមួយនូវតារាងរាយលម្អិតចំនួនទឹកប្រាក់ដែលត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានឆាប់រហ័ស ជាមួយនឹងការបង្កើត**ប្រតិបត្តិការបុរេប្រទានសម្រាប់ចំណាយប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ** (PO-Advanced) តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងស្កេនឯកសារពាក់ព័ន្ធឱ្យបានត្រឹមត្រូវ រួចបញ្ជូនទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ។ ផ្អែកតាមលិខិតអនុញ្ញាតផ្តល់បុរេប្រទានចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបញ្ជូនមកដល់រតនាគារថ្នាក់កណ្តាល យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ រតនាគារថ្នាក់កណ្តាល ត្រូវធ្វើការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ដំណាលគ្នានឹងការបើកផ្តល់បៀវត្សប្រចាំខែតុលា ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យភ្ជុំបិណ្ឌ។ ចំពោះក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទនៅថ្នាក់កណ្តាល ដែលខកខានពុំបានរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានបញ្ជូន



h

ទៅរតនាគារថ្នាក់កណ្តាល នោះរតនាគារថ្នាក់កណ្តាល ពុំមានមូលដ្ឋានក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌជូនឡើយ

-មន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានទៅរតនាគាររាជធានី ខេត្ត ដោយភ្ជាប់ជាមួយនូវតារាងរាយលម្អិតចំនួនទឹកប្រាក់ដែលត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ និងត្រូវចម្លងជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ០១ ច្បាប់។ យោងតាមលិខិតស្នើសុំថវិកាបុរេប្រទានរបស់មន្ទីរជំនាញរាជធានី ខេត្ត រតនាគាររាជធានី ខេត្ត ត្រូវធ្វើការបើកផ្តល់ថវិកាបុរេប្រទាននោះ ដំណាលគ្នានឹងការបើកផ្តល់បៀវត្សប្រចាំខែតុលា ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យភ្ជុំបិណ្ឌ។ ចំពោះមន្ទីរជំនាញរាជធានី ខេត្ត ដែលខកខានពុំបានរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានបញ្ជូនទៅរតនាគាររាជធានី ខេត្ត នោះរតនាគាររាជធានី ខេត្ត ពុំមានមូលដ្ឋានក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌជូនឡើយ។

**២.រដ្ឋបាលថ្នាក់ក្រោមជាតិ**

**២.១.ការបើកបៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែមេសា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ**

**ក.ករណីមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត"**

-រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវរួតរះរៀបចំលិខិតយុត្តិការចំណាយពាក់ព័ន្ធ និងបោះផ្សាយ **អាណត្តិបើកប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែមេសា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធី*បុណ្យ* ចូលឆ្នាំថ្មីប្រពៃណីជាតិ** ឱ្យបានទាន់ពេលវេលា រួចបញ្ជូនទៅ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបញ្ជូនទៅដល់រតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ដើម្បីធានាដល់ការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែមេសា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តែមួយលើក ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ

-រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវរួតរះរៀបចំលិខិតយុត្តិការចំណាយពាក់ព័ន្ធ និងបោះផ្សាយ **អាណត្តិបើកប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែមេសា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធី*បុណ្យ* ចូលឆ្នាំថ្មីប្រពៃណីជាតិ** ឱ្យបានទាន់ពេលវេលា និងដោយឡែក ចំពោះរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដែលអនុវត្តតាមប្រព័ន្ធ FMIS Portal ត្រូវរួតរះរៀបចំលិខិតយុត្តិការចំណាយពាក់ព័ន្ធ និងបោះផ្សាយអាណត្តិបើកប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែមេសា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ហើយស្កេនបញ្ចូលក្នុងប្រព័ន្ធ FMIS Portal រួចបញ្ជូនទៅរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ដើម្បីធានាដល់ការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែមេសា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តែមួយលើក ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។

**ខ.ករណីពុំមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត"**

-រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ទៅរតនាគាររាជធានី ខេត្ត ដោយភ្ជាប់ជាមួយនូវតារាងរាយលម្អិតចំនួនទឹកប្រាក់ដែល



14

ត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភ យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ និងត្រូវចម្លងជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ០១ ច្បាប់។ យោងតាមលិខិតស្នើសុំថវិកាបុរេប្រទានរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ រតនាគាររាជធានី ខេត្ត ត្រូវធ្វើការបើកផ្តល់ថវិកាបុរេប្រទាននោះ ដំណាលគ្នានឹងការបើកផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែមេសា ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ ចំពោះរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ដែលខកខានពុំបានរៀបចំលិខិតស្នើសុំថវិកាបុរេប្រទាន បញ្ជូនទៅរតនាគាររាជធានី ខេត្ត នោះរតនាគាររាជធានី ខេត្ត ពុំមានមូលដ្ឋានក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិជូនឡើយ

-រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ទៅរតនាគាររាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវតារាងរាយលម្អិតចំនួនទឹកប្រាក់ដែលត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភ និងដោយឡែក រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ត្រូវស្កេនលិខិតស្នើសុំថវិកាបុរេប្រទាន និងឯកសារពាក់ព័ន្ធ ដាក់បញ្ចូលទៅក្នុងប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ដើម្បីបញ្ជូនរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣។ រតនាគាររាជធានី ខេត្ត ត្រូវធ្វើការបើកផ្តល់ថវិកាបុរេប្រទាននោះ ដំណាលគ្នានឹងការបើកផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែមេសា ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ ចំពោះរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដែលខកខានពុំបានរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានបញ្ជូនទៅរតនាគាររាជធានី ខេត្ត នោះរតនាគាររាជធានី ខេត្ត ពុំមានមូលដ្ឋានក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិជូនឡើយ។

**២.២.ការបើកបៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែតុលា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ**

**ក.ករណីមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត"**

-រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវរៀបរៀបចំលិខិតយុត្តិការចំណាយពាក់ព័ន្ធ និងបោះផ្សាយ **អាណត្តិបើកប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែតុលា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ** ឱ្យបានទាន់ពេលវេលា រួចបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបញ្ជូនទៅដល់រតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ដើម្បីធានាដល់ការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែតុលា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ តែមួយលើកឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យភ្ជុំបិណ្ឌ

-រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបរៀបចំលិខិតយុត្តិការចំណាយពាក់ព័ន្ធ និងបោះផ្សាយអាណត្តិបើកប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែតុលា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ឱ្យបានទាន់ពេលវេលា និងដោយឡែក ចំពោះរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដែលអនុវត្តតាមប្រព័ន្ធ FMIS Portal ត្រូវរៀបរៀបចំលិខិតយុត្តិការចំណាយពាក់ព័ន្ធ និងបោះផ្សាយអាណត្តិបើកប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែតុលា ឆ្នាំ២០២៣ ដោយរួមបញ្ចូលប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ហើយស្កេនបញ្ចូលក្នុងប្រព័ន្ធFMIS Portal រួចបញ្ជូនទៅរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ដើម្បីធានាដល់ការបើកផ្តល់

បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែតុលា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ តែមួយលើកឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យភ្ជុំបិណ្ឌ។

**ខ.ករណីពុំមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត"**

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌទៅរតនាគាររាជធានី ខេត្ត ដោយភ្ជាប់ជាមួយនូវតារាងរាយលម្អិតចំនួនទឹកប្រាក់ដែលត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ និងត្រូវចម្លងជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ០១ ច្បាប់។ យោងតាមលិខិតស្នើសុំថវិកាបុរេប្រទានរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ រតនាគាររាជធានី ខេត្ត ត្រូវធ្វើការបើកផ្តល់ថវិកាបុរេប្រទាននោះ ដំណាលគ្នានឹងការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែតុលា ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យភ្ជុំបិណ្ឌ។ ចំពោះរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ដែលខកខានពុំបានរៀបចំលិខិតស្នើសុំថវិកាបុរេប្រទាន បញ្ជូនទៅរតនាគាររាជធានី ខេត្ត នោះរតនាគាររាជធានី ខេត្ត ពុំមានមូលដ្ឋានក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌជូនឡើយ

រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌទៅរតនាគាររាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវតារាងរាយលម្អិតចំនួនទឹកប្រាក់ដែលត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភ និងដោយឡែក រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ត្រូវស្កែនលិខិតស្នើសុំថវិកាបុរេប្រទាន និងឯកសារពាក់ព័ន្ធ ដាក់បញ្ចូលទៅក្នុងប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ដើម្បីបញ្ជូនរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣។ រតនាគាររាជធានី ខេត្ត ត្រូវធ្វើការបើកផ្តល់ថវិកាបុរេប្រទាននោះ ដំណាលគ្នានឹង ការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រចាំខែតុលា ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា មុនថ្ងៃពិធីបុណ្យភ្ជុំបិណ្ឌ។ ចំពោះរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដែលខកខានពុំបានរៀបចំលិខិតស្នើសុំថវិកាបុរេប្រទានបញ្ជូនទៅរតនាគាររាជធានី ខេត្ត នោះរតនាគាររាជធានី ខេត្ត ពុំមានមូលដ្ឋានក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌជូនឡើយ។

ក្នុងករណីរដ្ឋបាលថ្នាក់ក្រោមជាតិពុំមានឥណទានថវិកានៅក្នុងអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត" ប៉ុន្តែ គណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានសមតុល្យគ្រប់គ្រាន់ រតនាគាររាជធានី ខេត្ត ត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងពិធីបុណ្យភ្ជុំបិណ្ឌជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកតាមលិខិតស្នើសុំថវិកាបុរេប្រទាន។

ក្នុងករណីគណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពុំមានសមតុល្យគ្រប់គ្រាន់ រតនាគាររាជធានី ខេត្ត ត្រូវផ្តល់បុរេប្រទានសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មុននឹងបើកផ្តល់តាមអាណត្តិបើកប្រាក់ ឬ តាមលិខិតស្នើសុំថវិកាបុរេប្រទាន ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។

នៅពេលគណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានសមតុល្យគ្រប់គ្រាន់ រតនាគាររាជធានី ខេត្ត ត្រូវម្ចាស់ការ និងទទួលខុសត្រូវ ដោយធ្វើការកត់ត្រាជម្រះសមតុល្យគណនីបុរេប្រទាន ឬ រជ្ជទេយ្យបុរេប្រទានបានទទួល និងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានជ្រះស្រឡះ។



4

### ៣. វិធានការទូទាត់ថវិកាបុរេប្រទាន

#### ៣.១. រដ្ឋបាលថ្នាក់ជាតិ

ក្រោយពីបានបើកផ្តល់ប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការនិងបុគ្គលិក ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងអង្គភាពក្រោមឱវាទ ត្រូវរៀបចំលើកសំណើសុំបន្ថែមឥណទានថវិកាទៅអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បោះផ្សាយអាណត្តិនិយ័តកម្ម និង/ឬ បង្កើតប្រតិបត្តិការក្នុងប្រព័ន្ធ FMIS ទូទាត់ថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឱ្យបានជ្រះស្រឡះ យ៉ាងយូរបំផុតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៣ និងទូទាត់ថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌឱ្យបានជ្រះស្រឡះ យ៉ាងយូរបំផុតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ ជាកំហិត។

#### ៣.២. រដ្ឋបាលថ្នាក់ក្រោមជាតិ

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវពិនិត្យលទ្ធភាពឥណទានថវិការបស់ខ្លួន ដើម្បីបង្វែរចូលអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត" ដោយអនុវត្តតាមប្រកាសលេខ ១០៨ សហវ.ប្រក ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនៃការអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត

អភិបាលនៃគណៈអភិបាលខណ្ឌ ដែលអនុវត្តថវិកាកម្មវិធី ត្រូវពិនិត្យលទ្ធភាពឥណទានថវិការបស់ខ្លួន ដើម្បីបង្វែរឥណទានថវិកា ចូលអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត" ដោយអនុវត្តនីតិវិធីនិយ័តភាពឥណទានថវិកា តាមសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

អភិបាលនៃគណៈអភិបាលខណ្ឌ ដែលមិនទាន់អនុវត្តថវិកាកម្មវិធី ត្រូវពិនិត្យលទ្ធភាពឥណទានថវិកាជំពូក ៦៩ "ចំណាយមិនបានគ្រោងទុក" ឬ ជំពូកផ្សេងៗទៀត ដែលមានឥណទានថវិកាទំនេរ បន្ទាប់មកត្រូវរៀបចំសំណើសុំបង្វែរឥណទានថវិកាចូលអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត" មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈរដ្ឋបាលរាជធានីភ្នំពេញ

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវពិនិត្យលទ្ធភាពឥណទានថវិកាជំពូក ៦៩ "ចំណាយមិនបានគ្រោងទុក" ឬ ជំពូកផ្សេងៗទៀត ដែលមានឥណទានថវិកាទំនេរ បន្ទាប់មកត្រូវរៀបចំសំណើសុំបង្វែរឥណទានថវិកាចូលអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត" មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈរដ្ឋបាលខេត្ត។ ក្នុងករណីដែលរដ្ឋបាល ក្រុង ស្រុក ធ្វើការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ៦៤ "បន្ទុកបុគ្គលិក " ពីគណនី ឬ អនុគណនី ដែលមានឥណទានថវិកាទំនេរចូលអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត" ត្រូវស្នើសុំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក និងការអនុម័តយល់ព្រមពីគណៈអភិបាលខេត្ត

មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យលទ្ធភាពឥណទានថវិកាជំពូក ៦៩ "ចំណាយមិនបានគ្រោងទុក" ឬ ជំពូកផ្សេងៗទៀត ដែលមានឥណទានថវិកាទំនេរ បន្ទាប់មកត្រូវរៀបចំសំណើសុំបង្វែរឥណទានថវិកាចូលអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត" ទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីបញ្ជាក់ទទួលស្គាល់ការកែតម្រូវគម្រោងថវិកា។ ក្នុងករណីដែលរដ្ឋបាលឃុំ សង្កាត់ ធ្វើការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ៦៤ "បន្ទុកបុគ្គលិក" ពីគណនី ឬ អនុគណនី ដែលមាន



14

ឥណទានថវិកាទំនេរចូលអនុគណនី ៦៤៩៨១ "បន្ទុកបុគ្គលិកផ្សេងៗទៀត" ត្រូវមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សា ឃុំ សង្កាត់

បន្ទាប់ពីការបង្វែរឥណទានថវិកាត្រូវបានអនុញ្ញាត រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបោះផ្សាយអាណត្តិនិយ័តកម្ម ដោយមានភ្ជាប់សក្ខីប័ត្រពាក់ព័ន្ធដើម្បីធ្វើការទូទាត់ថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនេះឱ្យបានជ្រះស្រឡះ យ៉ាងយូរបំផុតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៣ និង ទូទាត់ថវិកាបុរេប្រទានប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌនេះឱ្យបានជ្រះស្រឡះ យ៉ាងយូរបំផុតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ ជាកំហិត។

ក្រោយពីទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។៚

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន÷**
-គ្រប់ក្រសួង ស្ថាប័ន
-អគ្គនាយកដ្ឋានរតនាគារជាតិ
-អគ្គនាយកដ្ឋានថវិកា
-អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
-គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៦ និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

### មាត្រា១ .-

ផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៦ ចំនួន ៥០ ០០០(ប្រាំម៉ឺន)រៀល និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ចំនួន ៥០ ០០០ (ប្រាំម៉ឺន)រៀលក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិលនៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីរាជការនៃអាជ្ញាធរសេវនកម្មជាតិ មន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មន្ត្រីខុទ្ទកាល័យដូចមានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន ទីប្រឹក្សា ជំនួយការ លេខាធិការ

និងមន្ត្រីដែលមានឋានៈស្មើដូចមានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីនៃការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតដែលកំពុងបម្រើការងារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយោធិននៃកងយោធពលខេមរភូមិន្ទ និងអតីតមន្ត្រីនគរបាលជាតិកម្ពុជា។ ចំពោះគ្រួសារជនពលីនិងគ្រួសារជនមរណៈ ជាអតីតយុទ្ធជន ត្រូវបានផ្តល់ជូនប្រាក់ឧបត្ថម្ភនេះ ចំនួន ៥០ ០០០(ប្រាំម៉ឺន)រៀល ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងចំនួន ៥០ ០០០(ប្រាំម៉ឺន)រៀល ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ក្នុងមួយគ្រួសារ។

ប្រាក់ឧបត្ថម្ភនេះត្រូវបានផ្តល់សម្រាប់ម្នាក់ៗ ឬមួយគ្រួសារតែមួយកន្លែងនិងមួយលើកប៉ុណ្ណោះ។

**មាត្រា២ ..**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភខាងលើ ត្រូវអនុវត្តឱ្យបានមុនថ្ងៃចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៦ និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ដោយត្រូវគោរពគោលការណ៍ ដូចខាងក្រោម៖

១. ការបើកផ្តល់ប្រាក់ឧបត្ថម្ភដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តតាមគណនីបៀវត្សរបស់សាមីជន ឬគ្រួសារជនពលីនិងគ្រួសារជនមរណៈ ជាអតីតយុទ្ធជន។

២. ក្រសួង ស្ថាប័ន និងអង្គភាពដែលមិនទាន់បានបើកគណនីបៀវត្សសម្រាប់មន្ត្រីរាជការ បុគ្គលិក និងភ្នាក់ងារសាធារណៈរបស់ខ្លួន ត្រូវចាត់ចែងការបើកផ្តល់ប្រាក់ឧបត្ថម្ភឱ្យបានដល់សាមីជនម្នាក់ៗគ្រប់ចំនួននិងទាន់ពេលវេលា។

៣. និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយោធិននៃកងយោធពលខេមរភូមិន្ទ និងអតីតមន្ត្រីនគរបាលជាតិកម្ពុជាដែលកំពុងបំពេញការងារជាមន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ ឬមុខតំណែងផ្សេងទៀតដែលមានបញ្ជាក់ក្នុងអនុក្រឹត្យនេះ ត្រូវទទួលប្រាក់ឧបត្ថម្ភតែមួយកន្លែងដែលចាត់ចែងបើកផ្តល់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៤. ក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវក្នុងការពិនិត្យផ្ទៀងផ្ទាត់ រៀបចំសំណើ និងធ្វើការបើកផ្តល់ប្រាក់ឧបត្ថម្ភដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ដោយមិនរាប់បញ្ចូលមុខសញ្ញានិវត្តជនក្នុងចំណុច៣ខាងលើ។

**មាត្រា៣ ..**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី ត្រូវសហការនិងចាត់ចែងរៀបចំការបើកផ្តល់ជាបុរេប្រទានសម្រាប់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីដំណាលគ្នាជាមួយនឹងការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែមេសាតែមួយលើកឱ្យបានដល់សាមីជនម្នាក់ៗយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភក្នុងឱកាសបុណ្យភ្ជុំបិណ្ឌដំណាលគ្នាជាមួយនឹងការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែតុលាតែមួយលើកឱ្យបានដល់សាមីជនម្នាក់ៗយ៉ាងយូរបំផុតត្រឹមថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។

ក្រសួង ស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវលើកសំណើជាក់ស្តែងអំពីចំនួនមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាការប្រញាប់ ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំប្រកាសបន្ថែមឥណទានថវិកាជូនទាន់ពេលវេលានិងធានាឱ្យការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះអនុវត្តបានទាន់ពេលវេលា។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងមុខងារសាធារណៈ**

**ហ៊ុំ សុខា**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ